ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៩១ ព.ណ.អ.ក.ពបប.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌតម្រូវហាឡាលកម្ពុជាសម្រាប់ផលិតផលគ្រឿងសម្អាង
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញនិងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ១២២ អនក្រ.បក ចុះថ្ងៃទី២៨ខែសីហា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា១០ មាត្រា១១ មាត្រា១៣ មាត្រា១៦ មាត្រា១៩ មាត្រា២៤ និងមាត្រា២៦ នៃអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- យោងប្រកាសលេខ១៣២ ពណអ.ក.ប.ប.ប្រក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- យោងប្រកាសលេខ១៣៣ ពណអ.ក.ប.ប.ប្រក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមឯកទេសផលិតផលហាឡាល នៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌតម្រូវលើការផលិត ការវេចខ្ចប់ផលិតផលគ្រឿងសម្អាងហាឡាលក្នុងគោលបំណងលើកកម្ពស់បច្ចេកទេសស្តង់ដារ អនាម័យ និងជំនឿទុកចិត្តពីសាសនិកឥស្លាមមកលើផលិតផលហាឡាលកម្ពុជាសម្រាប់ផ្គត់ផ្គង់ដល់ទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា និងជំរុញការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ រោងចក្រ សហគ្រាស និងសិប្បកម្មផលិត វេចខ្ចប់ផលិតផលគ្រឿងសម្អាង ដែលបានដាក់ពាក្យស្នើសុំប្រើប្រាស់ស្លាកសញ្ញា វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា។

**ប្រការ៣.-**

វាក្យស័ព្ទសំខាន់ៗមួយចំនួនដែលប្រើក្នុងប្រកាសនេះ មានអត្ថន័យដូចខាងក្រោម៖

១. **ច្បាប់ឥស្លាម ឬ SARI AT ISLAM ឬ** الشريعة الاسلامية (ជាភាសាអារ៉ាប់) សំដៅដល់ច្បាប់ដែលជនមុស្លីមត្រូវអនុវត្តតាមដោយផ្អែកលើគម្ពីរអាល់គួរអាន ស៊ុណ្ណះ អ៊ីច្មាក និងគីយ៉ាស ដែលទទួលស្គាល់ដោយនិកាយហាណាហ្វី ម៉ាលីគី ស្ហាហ្វីអ៊ី ហាំប៉ាលី។

២. **ហាឡាល ឬ HALAL ឬ** حلال (ជាភាសាអារ៉ាប់) សំដៅដល់វត្ថុណាមួយ ឬសេវាកម្មណាមួយដែលអនុញ្ញាតឱ្យប្រើប្រាស់ ឬឱ្យចូលរួម ដោយអាស្រ័យទៅតាមច្បាប់ឥស្លាម។ ពាក្យនេះត្រូវប្រើជាទូទៅទាក់ទងទៅនឹងផលិតផលម្ហូបអាហារ ផលិតផលសាច់ គ្រឿងសម្អាង ផលិតផលថែរក្សាខ្លួន ឱសថ អាហារបំប៉ន គ្រឿងផ្សំម្ហូបអាហារ និងសម្ភារប្រើប្រាស់ផ្សេងៗទៀត។

៣. **ហារ៉ាម (ហារ៉ាំ) ឬ HARAM ឬ** حرام (ជាភាសាអារ៉ាប់) មានន័យថា (បម្រាមដាច់ខាត) វត្ថុ ឬសកម្មភាពដែលច្បាប់ឥស្លាមបានហាមឃាត់ ឬអ្វីដែលផ្ទុយនឹងហាឡាល។

៤. **ណាជីស ឬ NAJIS ឬ** نجس (ជាភាសាអារ៉ាប់) មានន័យកខ្វក់ ភាពស្មោកគ្រោកដោយផ្ទុយនឹងហាឡាលដែលចាំបាច់ត្រូវតែលាងសម្អាតទើបទៅជាហាឡាល។ ណាជីសត្រូវបានបែងចែកចេញជា បី ប្រភេទ៖

   ក. ណាជីសមូខហ្វាហ្វាហ្វ ឬ NAJIS MUKHAFFAH ដូចជាទឹកនោមក្មេងប្រុសដែលមានអាយុក្រោម២ឆ្នាំ ដែលមិនទទួលទានអ្វីក្រៅពីទឹកដោះម្តាយ។

   ខ. ណាជីសមូតាវ៉ាស្សិតោះ ឬ NAJIS MUTAWASSITAH ដែលមានដូចជា៖

      - ឈាម កម្អួត ទឹកនោម លាមក ទឹករងៃ ខ្ទុះ។ល។ ដែលចេញមកពីសារពាង្គកាយមនុស្ស។

- រាល់វត្ថុរាវដែលនាំឱ្យមានជាតិពុល ដូចជាស្រាបៀរ ជាតិអាល់កុល ទឹកស្រវឹង ទឹកដែលមានសារធាតុពុល នាំឱ្យប៉ះពាល់សុខភាព។ល។
- រាល់ប្រភេទទឹកដោះរបស់សត្វដែលមិនហាឡាល។

គ. ណាជីសមូហ្គល់ឡាហ្សះ ឬ NAJIS MUGHLLAZAH ដែលមានដូចជា សត្វឆ្កែ ជ្រូក និងកូនកាត់នៃសត្វទាំងពីរនេះ។

៥. **មូតាណាជីស ឬ MUTANAJIS** សំដៅដល់វត្ថុហាឡាល ដែលមានទំនាក់ទំនងផ្ទាល់ ឬកខ្វក់ជាមួយវត្ថុណាជីស ដូច្នេះ មូតាណាជីសក្លាយទៅជាណាជីស។ មានវិធីសាស្ត្រមួយចំនួនដើម្បីសម្អាត មូតាណាជីស។

៦. **គ្រឿងសម្អាង** សំដៅដល់ផលិតផលដែលផ្សំឡើងដោយសារធាតុគីមី ជីវៈផលិតផល រុក្ខជាតិឬសិលាជាតិ សម្រាប់ប្រើលើបណ្តាផ្នែកខាងក្រៅនៃខ្លួនមនុស្ស (ស្បែក សក់ ក្រចក បបូរមាត់ និងផ្នែកខាងក្រៅអវយវៈភេទ) ឬប្រើលើធ្មេញ និងជាលិកាទន់នៃក្រអូមមាត់ ក្នុងគោលបំណងសម្អាត ការពារ ថែរក្សា ធ្វើឱ្យក្រអូប ផ្លាស់ប្តូររូបភាពខាងក្រៅ និងបំបាត់ក្លិនខ្លួន។

៧. **ការផលិត** សំដៅដល់ការកែច្នៃ លាយ ផ្សំ តម្លើង បង្កើត ឬការប្រែរូបភាព និងមានន័យសរុប ទាំងការប្តូរទ្រង់ទ្រាយ ការកែកុនទ្រង់ទ្រាយ ការចែកចាយ ការវេចខ្ចប់ ឬការរក្សាទុក។

៨. **ការវេចខ្ចប់** សំដៅដល់ការយកផលិតផលហាឡាលសម្រេចមកវេចខ្ចប់ ស្របតាមបច្ចេកទេសស្តង់ដារនៃផលិតផលហាឡាលកម្ពុជា។

៩. **សារពាង្គកាយកែប្រែហ្សែន (GMO)** សំដៅដល់សារពាង្គកាយដែលហ្សែន ត្រូវបានផ្លាស់ប្តូរដោយប្រើបច្ចេកទេសវិស្វកម្មហ្សែន។ សារពាង្គកាយដែលត្រូវបានកែប្រែហ្សែន រួមមានមីក្រូសរីរាង្គដូចជា បាក់តេរី និងផ្សិត សត្វល្អិត រុក្ខជាតិ ត្រី និងថនិកសត្វ។

## ប្រការ៤.-

បុគ្គលធ្វើធុរកិច្ច ផលិត វេចខ្ចប់គ្រឿងសម្អាងដែលមានបំណងស្នើសុំប្រើប្រាស់ស្លាកសញ្ញា វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១. អនុវត្តតាមគោលការណ៍អនុវត្តផលិតកម្មល្អ (GMP) ឬគោលការណ៍អនុវត្តផលិតកម្មល្អអប្បបរមា ដែលត្រូវបានទទួលស្គាល់ដោយក្រសួងស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នឯករាជ្យ។

២. បង្កើតក្រុមការងារបច្ចេកទេសហាឡាលផ្ទៃក្នុង ដើម្បីគ្រប់គ្រងដំណើរការផលិតកម្ម។

៣. មានលេខប្រវេទន៍ ឬលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

## ប្រការ៥.-

ផលិតផលគ្រឿងសម្អាងហាឡាល ត្រូវមានគុណភាព សុវត្ថិភាព និងស្របតាមច្បាប់ឥស្លាមដោយត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១. គ្មានផ្ទុកនូវសារធាតុណាមួយដែលជាផ្នែក ឬត្រូវបានបំលែងចេញពីសរីរាង្គមនុស្ស។

២. គ្មានផ្ទុកនូវសារធាតុណាមួយដែលជាផ្នែក ឬត្រូវបានបំលែងចេញពីសរីរាង្គសត្វដែលត្រូវបានហាមឃាត់ ឬមិនត្រូវបានសំឡេះដោយអនុវត្តស្របតាមច្បាប់ឥស្លាម។

៣. គ្មានផ្ទុកនូវសមាសធាតុ ឬសារពាង្គកាយកែប្រែហ្សែន (GMO) ដែលចាត់ជាណាជីស ស្របតាមច្បាប់ឥស្លាម។
៤. មិនត្រូវរៀបចំដំណើរការ កែច្នៃ ផលិត ឬរក្សាទុកដោយប្រើប្រាស់សម្ភារដែលចម្លងជាមួយវត្ថុមិនស្អាត (ណាជីស) ស្របតាមច្បាប់ឥស្លាម។
៥. ក្នុងកំឡុងពេលរៀបចំ កែច្នៃ ឬផលិត មិនត្រូវឱ្យប៉ះពាល់និងត្រូវញែកចេញពីសារធាតុដែលមិនគោរពតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងចំណុច១, ២, ៣ ឬចំណុច៤ ខាងលើ
៦. មិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់។

**ប្រការ៦.-**

ប្រភពនៃវត្ថុធាតុដើម ឬសមាសធាតុផ្សំដែលអនុញ្ញាតសម្រាប់ការផលិតគ្រឿងសម្អាងហាឡាលមានដូចខាងក្រោម៖

១. សត្វរស់នៅលើគោក និងសត្វរស់នៅក្នុងទឹក៖
   ក. សត្វហាឡាលរស់នៅលើគោកគ្រប់ប្រភេទ និងត្រូវបានសំឡេះស្របតាមច្បាប់ឥស្លាម។ ចំពោះរោម សក់ និងផ្នែកផ្សេងៗទៀតដែលយកមកប្រើប្រាស់ត្រូវតែយកចេញពីសត្វមានជីវិត។
   ខ. ស៊ុតគ្រប់ប្រភេទ ដែលទទួលបានពីសត្វមិនមែនណាជីស ត្រូវចាត់ទុកជាហាឡាល។
   គ. សត្វហាឡាលរស់ក្នុងទឹកគ្រប់ប្រភេទចាត់ទុកជាប្រភពសម្រាប់ប្រើប្រាស់ ក្នុងការផលិតគ្រឿងសម្អាង។
២. រុក្ខជាតិ និងអតិសុខុមប្រាណ ដែលមាននៅលើដី ខ្យល់ និងទឹក ទាំងអស់ត្រូវចាត់ទុកជាហាឡាល លើកលែងតែរុក្ខជាតិ ឬអតិសុខុមប្រាណ ដែលអាចបង្កគ្រោះថ្នាក់ និង/ឬមានលាយផ្សំជាមួយណាជីស ឬហារ៉ាម។
៣. ប្រភពសមាសធាតុទាំងអស់ដែលទទួលបានមកពីដី ទឹក និងផលិតផលបន្ទាប់បន្សំ(រួមមានសារធាតុរ៉ែ) ត្រូវចាត់ទុកជាហាឡាល លើកលែងតែសមាសធាតុដែលអាច បង្កគ្រោះថ្នាក់ និង/ឬមានលាយផ្សំជាមួយសារធាតុដែលចាត់ទុកថាជាណាជីស។
៤. អាល់កុល ដែលប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ផលិតគ្រឿងសម្អាង ត្រូវបានអនុញ្ញាត លើកលែងតែភេសជ្ជៈមានជាតិអាល់កុល។
៥. សារធាតុសំយោគ ដែលប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ផលិតគ្រឿងសម្អាង ចាត់ទុកជាហាឡាល លើកលែងតែសារធាតុសំយោគនោះបង្កគ្រោះថ្នាក់ និង/ឬមានលាយផ្សំជាមួយសារធាតុដែលចាត់ទុកថាជាណាជីស។

**ប្រការ៧.-**

បុគ្គលធ្វើធុរកិច្ច ផលិត វេចខ្ចប់គ្រឿងសម្អាងហាឡាល ត្រូវចាត់ចែង គ្រប់គ្រងអនាម័យក្នុងការរៀបចំនិងសហគ្គាករណ៍នូវសម្ភារ ឬផលិតផលគ្រឿងសម្អាងដូចខាងក្រោម៖

១. រក្សាភាពស្អាតគ្រប់ផ្នែកទាំងអស់ មានជាអាទិ៍ អនាម័យផ្ទាល់ខ្លួន សម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់ និងទីតាំងផលិត សម្ភារ ឬផលិតផលសម្រាប់គ្រឿងសម្អាង។

២. ការពារមិនឱ្យមានការចម្លងសមាសធាតុណាជីស ភាពកខ្វក់ អតិសុខុមប្រាណ និងសារធាតុចម្លងផ្សេងៗទៀតដែលបង្កគ្រោះថ្នាក់។ បុគ្គលិក និងភ្ញៀវដែលចូលទៅកាន់ទីតាំងផលិត វេចខ្ចប់គ្រឿងសម្អាងហាឡាល ត្រូវពាក់សម្លៀកបំពាក់ការពារឱ្យបានសមរម្យ និងប្រើប្រាស់ឧបករណ៍ស្របតាមបទប្បញ្ញត្តិដែលកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។

**ប្រការ៨.-**

ដើម្បីធានាថាផលិតផលគ្រឿងសម្អាងដែលបានផលិត ពិតជាផលិតផលហាឡាល បុគ្គលស្នើសុំប្រើប្រាស់ស្លាកសញ្ញា វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវចាត់ចែង រៀបចំសហគ្គាករណ៍ និងការចែកចាយ ផលិតផលទាំងនោះត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវ ដូចខាងក្រោម៖

១. ខ្សែចង្វាក់ផលិតកម្ម ឧបករណ៍ និងសម្ភារប្រើប្រាស់ គឺត្រូវប្រើប្រាស់សម្រាប់តែការផលិតផលិតផលហាឡាលប៉ុណ្ណោះ។

២. ផលិតផល ឬសមាសធាតុផ្សំរបស់វា ពុំមានសមាសធាតុ ឬផលិតផលដែលផ្សំចេញពីសត្វដែលមិនមែនហាឡាល ឬផ្សំចេញពីសត្វដែលមិនបានសំឡេះតាមច្បាប់ឥស្លាម។

៣. ផលិតផលនោះ ពុំមានសមាសធាតុកខ្វក់ទោះបីជាក្នុងបរិមាណតិចតួចក៏ដោយ ដែលចាត់ទុកជាណាជីសតាមច្បាប់ឥស្លាម។

៤. ផលិតផលនោះ ឬសមាសធាតុផ្សំរបស់វា មានសុវត្ថិភាព និងមិនបង្កគ្រោះថ្នាក់។

៥. ផលិតផល ត្រូវបានរៀបចំ កែច្នៃ ឬផលិត ដោយប្រើប្រាស់ឧបករណ៍ និងសម្ភារដែលមិនមានការចម្លងជាមួយណាជីស។

៦. ក្នុងអំឡុងពេលនៃការរៀបចំ កែច្នៃ វេចខ្ចប់ រក្សាទុក ឬការដឹកជញ្ជូន ត្រូវដាក់ឱ្យដាច់ដោយឡែកពីវត្ថុផ្សេងទៀត ដែលមិនបានគោរពតាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ១, ២, ៣, ៤ និង/ឬ ៥ ឬវត្ថុផ្សេងទៀតដែលត្រូវបានចាត់ទុកថាជាណាជីសស្របតាមច្បាប់ឥស្លាម។

**ប្រការ៩.-**

បុគ្គលស្នើសុំប្រើប្រាស់ស្លាកសញ្ញា វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវរៀបចំឧបករណ៍ សម្ភារ គ្រឿងម៉ាស៊ីន និងសម្ភារជំនួយក្នុងការផលិតគ្រឿងសម្អាងហាឡាលតាមលក្ខខណ្ឌតម្រូវ ដូចខាងក្រោម៖

១. មិនត្រូវផលិតចេញពី ឬមានសារធាតុដែលចាត់ទុកថាជាណាជីស ហើយត្រូវប្រើប្រាស់ឧបករណ៍ សម្ភារ គ្រឿងម៉ាស៊ីន និងសម្ភារជំនួយទាំងនោះ សម្រាប់តែការផលិត កែច្នៃ វេចខ្ចប់គ្រឿងសម្អាងហាឡាលតែប៉ុណ្ណោះ។

២. ឧបករណ៍ សម្ភារ និងគ្រឿងម៉ាស៊ីនប្រើប្រាស់ ដែលធ្លាប់ប្រើពីមុន ឬបានប៉ះពាល់ជាមួយណាជីសមូហ្គល់ឡាហេហ្វ្រះ ត្រូវលាងសម្អាតឱ្យបានត្រឹមត្រូវ និងស្របតាមច្បាប់ឥស្លាម។

៣. ក្នុងករណីកែប្រែចង្វាក់ផលិតកម្មពីណាជីសមូហ្គល់ឡាហេហ្វ្រះ ឬខ្សែចង្វាក់ផលិតកម្មដែលមានណាជីសមូហ្គល់ឡាហេហ្វ្រះ មកខ្សែចង្វាក់ផលិតកម្មហាឡាលវិញ ចង្វាក់ផលិតកម្មនោះ ត្រូវលាងសម្អាតដោយស្របតាមច្បាប់ឥស្លាម។ ការផ្លាស់ប្តូរខ្សែចង្វាក់ផលិតកម្មពីណាជីសមូហ្គល់ឡាហេហ្វ្រះ មកខ្សែចង្វាក់ផលិតកម្មហាឡាលត្រូវអនុញ្ញាតឱ្យធ្វើបានតែមួយលើកគត់។

**ប្រការ១០.-**

បុគ្គលស្នើសុំប្រើប្រាស់ស្លាកសញ្ញា វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវវេចខ្ចប់គ្រឿងសម្អាងហាឡាលក្នុងលក្ខខណ្ឌស្អាត និងមានអនាម័យ។ សំបកវេចខ្ចប់គ្រឿងសម្អាងហាឡាល ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

១. មិនត្រូវបានផលិតពីវត្ថុធាតុដើមដែលចាត់ទុកជាណាជីស។

២. មិនត្រូវបានរៀបចំ កែច្នៃ ឬផលិតឡើងដោយប្រើឧបករណ៍ដែលមានការចម្លង វត្ថុធាតុដែលមិនស្អាត ហើយចាត់ទុកថាជាណាជីស។

៣. ក្នុងអំឡុងពេលរៀបចំ ផលិត រក្សាទុក និងដឹកជញ្ជូន សំបកវេចខ្ចប់ត្រូវដាក់ឱ្យដាច់ពីវត្ថុផ្សេងទៀត ដែលមិនអនុលោមតាមលក្ខខណ្ឌតម្រូវដូចបានកំណត់ខាងលើចំណុច ១ ឬ ២ ឬវត្ថុផ្សេងទៀតដែល ចាត់ទុកថាជាណាជីស។

៤. មិនត្រូវមានសារធាតុបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស។

**ប្រការ១១.-**

គ្រឿងសម្អាងហាឡាល ត្រូវដាក់ស្លាកសញ្ញាឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានព័ត៌មានដែលមានជាធរមាន និងស្របតាមច្បាប់ឥស្លាម។

**ប្រការ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣.-**

សមាសភាពគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ប្រធានក្រុមឯកទេសផលិតផលហាឡាល និងប្រតិបត្តិករអាជីវកម្មគ្រឿងសម្អាងហាឡាល ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/

ថ្ងៃសុក្រ ៥កើត ខែផល្គុន ឆ្នាំខាលចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធាន**

**គណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា
- ដូចប្រការ ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ